មេរៀនទី២

# សង្គ្រាមលោកលើកទី២ (1939-1945)

សង្គ្រាមលោកលើកទី2 ចាប់ពីឆ្នាំ 1939-1945 បានធ្វើអោយមនុស្សជាតិបានស្គាល់ការខូតខាតឥតគណនា។ នេះជាមហិច្ឆតារបស់ពួក ហ្វាស៊ីល អ៊ីតាលី ណាស៊ី អាឡឺម៉ង់ និង យោធានិយមជប៉ុនដែលចង់ត្រួតត្រាពិភពលោក។

## ៙ មូលហេតុនៃសង្គ្រាម

មូលហេតុសំខាន់ៗដែលនាំអោយកើតមហាសង្គ្រាមលោក ផ្ទុះឡើងមានបីចំនុចសំខាន់ៗ គឺ:

- ***បញ្ហាសេដ្ឋកិច្ច***: អាឡឺម៉ង់បានក្លាយជាមហាអំណាចមួយយ៉ាងរឹងមាំ នៅក្នុងចំណោមប្រទេសនៅ អ៊ឺរ៉ុប ហើយស្វែងរកទីផ្សាពិភពលោកដើម្បីលក់ផលិត ផលរបស់ខ្លួនដែលធ្វើអោយប៉ះពាល់ទីផ្សាពិភពលោករបស់ពួក អង់គ្លេស បារាំង និង អាមេរិច។
- ***បញ្ហានយោបាយ***: ការចុះខ្សោយនៃសង្គមប្រជាជាតិធ្វើអោយ អាឡឺម៉ង់ ហែក សន្ធិសញ្ញាក្រុងវែសៃ ចោយដើម្បីសម្រេច នយោបាយត្រួតត្រាពិភពលោក។
- ***បញ្ហាយោធា***: កងទ័ព អាឡឺម៉ង់ បានប្រែក្លាយទៅជាកងទ័ពមួយយ៉ាងសាហាវឃោឃៅ ខ្លាំងពូកែ បំពាក់ដោយអាវុធយុទ្ធភណ្ឌទំនើបៗ មានការហ្វឹកហាត់យ៉ាងតឹងរឹង។

## ៙ កម្លាំងប្រឈមគ្នា

សង្គ្រាមលោកលើកទី2 មានកម្លាំងពីរប្រឈមគ្នាគឺ:

- ប្លុកទី1 ***សម្ព័ន្ធត្រីភាគី***: មាន អាឡឺម៉ង់ ជប៉ុន អ៊ីតាលី។
- ប្លុកទី2 ***អនុសញ្ញាត្រីភាគី***: មាន អង់គ្លេស បារាំង រុស្ស៊ី អាមេរិច។

## ៙ ដំណាក់កាលសំខាន់ៗ នៃសង្គ្រាមលោកលើកទី2

- ***ការវាយលុកនៃកងទ័ពអាឡឺម៉ង់ អ៊ីតាលី ជប៉ុន ចាប់ពីឆ្នាំ 1941***
  កងទ័ពអាឡឺម៉ង់បានវាយយកប្រទេសប៉ូឡូញ ដាណឺម៉ាក ប៊ែលហ្សិក ហូឡង់ ន័រវេស បារាំង យូហ្គោស្លាវី ក្រិច។ នៅឆ្នាំ 1941 អាឡឺម៉ង់បានវាយប្រហាទៅលើប្រទេសរុស្ស៊ីដោយមិនបានប្រកាសជាមុន។ កងទ័ពអាកាសជប៉ុនបានវាយប្រហារទៅលើ នាវាចម្បាំងរបស់អាមេរិច នៅក្នុងសមុទ្រ ប៉ាស៊ីភិច ដោយមិនប្រកាសជាមុន បណ្តាលឲ្យខូតខាតនាវាចម្បាំងអាមេរិចយ៉ាងដំណំ ជាហេតុធ្វើឲ្យអាមេរិច ចូលលូកដៃក្នុងសង្គ្រាមលោកលើកទី2 នាថ្ងៃ 7 ធ្នូ 1941។ នៅអាស៊ីកងទ័ពជប៉ុន ដណ្តើមបានទីក្រុងហុងកុង ហ្វីលីពីន ឥណ្ឌូនេស៊ី សឹង្ហបុរី ម៉ាលេស៊ី ភូមា ថៃ .....តែក្នុងរយះពេល 2 ឬ 3 ខែប៉ុណ្ណោះ។
- ***ការទប់ទល់របស់កងទ័ព រុស្ស៊ី និង អង់គ្លេស*** រុស្ស៊ីវាយដណ្តើមបានក្រុង ស្តាលីន ក្រាត មកវិញនៅខែ កុម្ភះ 1943 និង បន្តការវាយសំរុក ធ្វើអោយអាឡឺម៉ង់ បរាជ័យ ដកកងទ័ពថយពីគ្រប់សមរភូមិ។ ទ័ពអង់គ្លេសដោយមានជំនួយពីកងទ័ពបារាំង និង ទ័ពអាមេរិច បានរួមដៃគ្នាដេញប្រហារ និង រុញច្រានកងទ័ពអ៊ីតាលី និង អាឡឺម៉ង់ពីប្រទេសអេហ្ស៊ីប រហូតដល់ប្រទេស ទុយនេស៊ី និង បន្តការរុញច្រានរហូតដល់ កោះស៊ីស៊ីល ក្នុងប្រទេស អ៊ីតាលី តែម្តងដោយធ្វើអោយអ៊ីតាលីចុះហត្ថលេខា លើយុទ្ធសន្តិភាពជាមួយអង់គ្លេស និង អាមេរិច បញ្ចប់សង្គ្រាមនៅអ៊ីតាលី។
- ***ការវាសម្រុករបស់កងទ័ពសម្ព័ន្ធមិត្តឆ្នាំ 1944***
  កងទ័ពអង់គ្លេស និង កងទ័ពអាមេរិច បានប្រមូលផ្តុំគ្នានៅអង់គ្លេស បានតាមវាយប្រហា កងទ័ពអាឡឺម៉ង់ ដល់ទីក្រុង ប៉ារីស និង រំដោះទីក្រុងនេះនៅខែ សីហា 1944។

## ៙ ការបរាជ័យរបស់អ៊ីតាលី អាឡឺម៉ង់ និង ជប៉ុន

- អ៊ីតាលីចុះចាញ់នៅថ្ងៃទី 3 កញ្ញា 1943 ដោយកងទ័ពសម្ព័ន្ធមិត្តឡើងកោះស៊ីស៊ីល
- អាឡឺម៉ង់ចុះចាញ់នៅថ្ងៃទី 7,8 ឧសភា 1945 ដោយសាកងទ័ពរុស្ស៊ីកាន់កាប់បានទីក្រុង ប៊ែឡាំង ហើយលោក អ៊ីទ្លែ បានធ្វើអត្តឃាតសម្លាប់ខ្លួន ឯងនៅថ្ងៃទី 30 មេសា 1945
- ជប៉ុនចុះចាញ់នៅថ្ងៃទី2 កញ្ញា 1945 ដោសារ:
  + កោះអូគីណាវាបានទៅអាមេរិច
  + ប្រធានាធិបតេយ្យអាមេរិចបញ្ជាអោយទម្លាក់គ្រាប់បរមាណូនៅទីក្រុងចំនួនពីរនៅក្នុងប្រទេសជប៉ុន
  1- ទីក្រុងហ៊ីរ៉ូស៊ីម៉ា នៅថ្ងៃទី 6 សីហា 1945
  2- ទីក្រុងណាកាសាគី នៅថ្ងៃទី 9 សីហា 1945

## ៙ ផលវិបាកក្នុងសង្គ្រាមលោកលើកទី2

សង្គ្រាមលោកលើកទី2 ដែលផ្តើមពីថ្ងៃទី 1 កញ្ញា 1939 រហូតដល់ 2 កញ្ញា 1945 នៅក្នុងទ្វីបអ៊ឺរ៉ុប អាស៊ី អាព្រិច បានសម្លាប់មនុស្ស អស់ 55លាននាក់ ក្នុងនោះទ្វីបអ៊ឺរ៉ុបអស់ 45 លាននាក់ និង បំផ្លាញទីក្រុងព្រមទាំងសំភារះអស់ជាច្រើនឥតគណនា។

បង្រៀនដោយលោកគ្រូ អ៊ូ សៅ
មុខវិជ្ជា ប្រវត្តិវិទ្យា ថ្នាក់ទី៩
សូមសំណាងល្អពេលប្រលង